

# នីតិវិធីដែលចាំបាច់នៅពេលទទួលប្រាក់ឈ្នួលតាម"ប្រព័ន្ធឌីជីថល”

**សម្រាប់កម្មករនិយោជិត**

តាមរយៈច្បាប់ស្តីពីស្តង់ដាការងារ ប្រាក់ឈ្នួលជាគោលការណ៍ត្រូវទូទាត់ដោយសាច់ប្រាក់ ប៉ុន្តែក្នុងករណីមានការយល់ព្រមពីកម្មករនិយោជិត ការទូទាត់ប្រាក់ឈ្នួលដោយការវេរចូលគណនីធនាគារជាដើមត្រូវបានអនុញ្ញាត។ដើម្បីឆ្លើយតបនឹងតម្រូវការនៃការកើនឡើងនូវការទូទាត់ដោយគ្មានសាច់ប្រាក់និងការផ្តល់ជម្រើសច្រើននូវនីតិវិធីផ្ទេរប្រាក់ ក្នុងករណីមានការយល់ព្រមពីកម្មករនិយោជិត ការទូទាត់ប្រាក់ឈ្នួល(ការទូទាត់ប្រាក់ឈ្នួលតាមប្រព័ន្ធឌីជីថល)ទៅកាន់គណនីរបស់ភ្នាក់ងារផ្ទេរប្រាក់(ដូចជា●●Payជាដើម)ដែលបានកំណត់ដោយរដ្ឋមន្ត្រីក្រសួងសុខាភិបាលការងារ និងសុខុមាលភាពក៏បានអនុញ្ញាតផងដែរ។



សម្រាប់ព័ត៌មានលម្អិតទាក់ទងនឹងប្រព័ន្ធទូទាត់ប្រាក់ឈ្នួលតាមប្រព័ន្ធឌីជីថល និងភ្នាក់ងារផ្ទេរប្រាក់ដែលកំណត់ដោយរដ្ឋមន្ត្រីក្រសួងសុខាភិបាលការងារ និងសុខុមាលភាព(ភ្នាក់ងារផ្ទេរប្រាក់ដែលបានកំណត់)សូមចូលទៅកាន់គេហទំព័ររបស់ក្រសួងសុខាភិបាលការងារ និងសុខុមាលភាព”ឯកសារព័ត៌មាន” ”បញ្ជីភ្នាក់ងារផ្ទេរប្រាក់ដែលបានកំណត់”ល

គេហទំព័ររបស់ក្រសួងសុខាភិបាលការងារ និងសុខុមាលភាព

## 1 ចំពោះការទទួលប្រាក់ឈ្នួលដោយការទូទាត់តាមប្រព័ន្ធឌីជីថល

**★នៅក្នុងខិតប័ណ្ណនេះ សម្រាប់អ្នកដែលមានបំណងចង់ទូទាត់ប្រាក់ឈ្នួលតាមប្រព័ន្ធឌីជីថល យើងបានចងក្រងព័ត៌មានខ្លឹមសារដើម្បីអាចឆ្លើយតបនឹងតម្រូវការ និងចង់អោយអ្នកទាំងអស់គ្នាដែលជាកម្មករនយោជិតយល់ដឹង។**

● ចំពោះការទទួលប្រាក់ឈ្នួលដោយការទូទាត់តាមប្រព័ន្ធឌីជីថល ត្រូវបានសន្និដ្ឋានថា ក្រុមហ៊ុនដែលអ្នកធ្វើការ បានធ្វើកិច្ចព្រមព្រៀងការងារ ទាក់ទងនឹង ការទូរទាត់ប្រាក់ឈ្នួលតាមប្រព័ន្ធឌីជីថល ។លើសពីនេះ ក្នុងកិច្ចព្រមព្រៀងការងារ ភ្នាក់ងារផ្ទេរប្រាក់ដែលអាចប្រើបានគឺត្រូវបានកំណត់ដោយក្រុមហ៊ុនដែលអ្នកធ្វើការ។

※ចំពោះកិច្ចព្រមព្រៀងការងារ ករណីមានសហជីពដែលរៀបចំដោយកម្មករនិយោជិតភាគច្រើន គឺសហជីពនោះជាអ្នកកំណត់、 ប្រសិនបើមិនមានសហជីពរៀបចំដោយកម្មករនិយោជិតភាគច្រើននោះទេ នឹងត្រូវបានកំណត់ដោយអ្នកតំណាងអោយកម្មករនិយោជិតភាគច្រើន និងនិយោជក ។



សម្រាប់អ្នកដែលកំពុងធ្វើការនៅក្រុមហ៊ុនដែលមិនបានណែនាំពីការទូរទាត់ប្រាក់ឈ្នួលតាមប្រព័ន្ធឌីជីថល ករណីអ្នកចង់ទទួលប្រាក់ឈ្នួលដោយការទូរទាត់ប្រាក់ឈ្នួលតាមប្រព័ន្ធឌីជីថលឬក្នុងករណីអ្នកចង់ប្រើប្រាស់ភ្នាក់ងារផ្ទេរប្រាក់ដែលមិនរាប់បញ្ចូលក្នុងកិច្ចព្រមព្រៀងការងារ សូមប្រឹក្សាយោបល់ជាមួយក្រុមហ៊ុនឬសហជីពរបស់អ្នក

### ⚠ ប្រការប្រុងប្រយ័ត្ន

- មិនមានការបង្ខំអោយមានការទូទាត់ប្រាក់ឈ្នួលតាមប្រព័ន្ធឌីជីថលនោះទេ។ លើសពីនេះ ប្រសិនបើកម្មករនិយោជិតមិនមានបំណងប្រើប្រាស់នោះទេ គាត់ក៏អាចទទួលបានប្រាក់ឈ្នួលតាមរយៈគណនីធនាគារបានដូចធម្មតា។
- កម្មករនិយោជិតក៏អាចទទួលបានប្រាក់ឈ្នួលមួយផ្នែកតាមការទូទាត់តាមប្រព័ន្ធឌីជីថល ហើយផ្នែកដែលនៅសល់ក៏អាចទទួលបានប្រាក់ឈ្នួលតាមរយៈគណនីធនាគារបានដូចធម្មតាផងដែរ។ទោះបីជ
- ាបានជ្រើសរើសការទូទាត់ប្រាក់ឈ្នួលតាមប្រព័ន្ធឌីជីថលក៏ដោយ បន្ទាប់ពីនោះអ្នកក៏អាចផ្លាស់ប្តូរវិធីសាស្ត្រនៃការទទួលប្រាក់ឈ្នួលតាមគណនីធនាគារជាដើម បានផងដែរ។

# លំដាប់លំដោយនីតិវិធីចាំបាច់

● ក្នុងករណីដែលមានបំណងចង់ទទួលប្រាក់ឈ្នួលដោយការទូទាត់តាមប្រព័ន្ធឌីជីថល នីតិវិធីដែលចាំបាច់មានដូចខាងក្រោម

①ការពិនិត្យមើលខ្លឹមសារសេវាកម្មនៃភ្នាក់ងារផ្ទេរប្រាក់ដែលបានកំណត់នីមួយៗ

②ការយល់ព្រមជាលក្ខណ:បុគ្គលទៅកាន់និយោជក។ល។

③ការដាក់ពាក្យស្នើរសុំទៅកាន់ភ្នាក់ងារផ្ទេរប្រាក់ដែលបានកំណត់




## 1 ការពិនិត្យមើលខ្លឹមសារសេវាកម្មនៃភ្នាក់ងារផ្ទេរប្រាក់ដែលបានកំណត់នីមួយៗ

● ក្នុងចំនោមភ្នាក់ងារផ្ទេរប្រាក់ដែលបានកំណត់ដោយកិច្ចព្រមព្រៀងការងារ សូមពិចារណាថាតើអ្នកនឹងប្រើប្រាស់ភ្នាក់ងារផ្ទេរប្រាក់មួយណា។ ដោយសារតែខ្លឹមសារនៃសេវាកម្មវាខុសគ្នាអាស្រ័យលើភ្នាក់ងារផ្ទេរប្រាក់ដែលបានកំណត់ ដូច្នេះពេលពិចារណាសូមពិនិត្យមើលព័ត៌មានលំអិតនៅគេហទំព័រភ្នាក់ងារផ្ទេរប្រាក់ដែលបានកំណត់នីមួយៗ។ល។ លើសពីនេះទៅទៀត អ្នកក៏អាចជ្រើសរើសភ្នាក់ងារផ្ទេរប្រាក់ដែលបានកំណត់ចំនួនច្រើនផងដែរ។

### ចំណុចដែលត្រូវពិចារណាលើភ្នាក់ងារផ្ទេរប្រាក់ដែលបានកំណត់

■ **មានកំណត់ចំនួនទឹកប្រាក់អតិបរមាដែលអាចទទួលក្នុងគណនីធនាគារដែលទទួលប្រាក់ឈ្នួល(គណនី)**

ចំនួនទឹកប្រាក់អតិបរមាដែលអាចទទួល គឺខុសគ្នាទៅតាមភ្នាក់ងារផ្ទេរប្រាក់ដែលបានកំណត់។ក្នុងករណីលើសពីចំនួនទឹកប្រាក់អតិបរមាដែលអាចទទួល ចំនួនទឹកប្រាក់ដែលលើសនោះនឹងដកដោយស្វ័យប្រវត្តិទៅកាន់គណនីសន្សំធនាគារដែលអ្នកបានកំណត់(គណនីជំនួសដែលបានកំណត់)។

ក្នុងករណីនេះថ្លៃសេវាដែលដកដោយស្វ័យប្រវត្តិទៅកាន់គណនីជំនួសដែលបានកំណត់ អាចជាបន្ទុករបស់  កម្មករនិយោជិត។

■ **ពិនិត្យមើលថ្លៃសេវានិងវិធីសាស្រ្តសម្រាប់ដកសាច់ប្រាក់ពីសមតុល្យគណនី(ការដកប្រាក់)**

អ្នកក៏អាចដកសាច់ប្រាក់(ដកប្រាក់)ពីសមតុល្យគណនីដោយដកប្រាក់នៅម៉ាស៊ីនATMឬគណនីធនាគារជាដើមបានផងដែរ  អ្នកអាចដកប្រាក់ពីគណនីរបស់អ្នកយ៉ាងហោច1ដងក្នុងមួយខែដោយមិនគិតថ្លៃសេវា។ សូមបញ្ជាក់ថា គោលដៅដកប្រាក់និងថ្លៃសេវាដែលដកប្រាក់ចាប់ពីលើកទី 2 ទៅគឺខុសគ្នាទៅតាមភ្នាក់ងារផ្ទេរប្រាក់ដែលបានកំណត់។

## 2 ការយល់ព្រមជាលក្ខណៈបុគ្គលទៅកាន់និយោជក។ល។

● បន្ទាប់ពីទទួលបានការពន្យល់ពីនិយោជក(ឬក៏ភ្នាក់ងារផ្ទេរប្រាក់ដែលបានកំណត់)អំពីចំណុចចាំបាច់ទាក់ទងនឹងការទូទាត់ប្រាក់ដោយប្រព័ន្ធឌីជីថលរួចហើយ សូមដាក់ឯកសារព្រមព្រៀងទាក់ទងនឹងការទូទាត់ប្រាក់ដោយប្រព័ន្ធឌីជីថលរបស់អ្នក។ហើយជាមួយគ្នានឹងការយល់ព្រមនេះ អ្នកចាំបាច់ត្រូវប្រាប់នូវចំណុចខាងក្រោមដែលអ្នកបានសម្រេចចិត្តទៅកាន់និយោជក។

(1) ទំហំនិងបរិមាណប្រាក់ឈ្នួលដែលចង់ទទួលដោយការទូទាត់ឌីជីថល

(2) ឈ្មោះភ្នាក់ងារផ្ទេរប្រាក់ដែលបានកំណត់(សេវាកម្ម) និងព័ត៌មានគណនីដែលជាគោលដៅទទួលប្រាក់ឈ្នួល
（ឧ：IDគណនី、ឈ្មោះអ្នកទទួល）

(3) កាលបរិច្ឆេទដែលមានបំណងចាប់ផ្តើមបង់ប្រាក់

(4) ព័ត៌មានអំពីគណនីជំនួសដែលបានកំណត់ដូចជាធនាគារជាដើម



គណនីភ្នាក់ងារផ្ទេរប្រាក់ដែលបានកំណត់ គឺមិនមែនសម្រាប់ "ដាក់ប្រាក់"នោះទេ សូមយល់ថាវាប្រើសម្រាប់ទូទាត់និងផ្ញើរប្រាក់ ដូច្នេះសូមកំណត់ចំនួនទឹកប្រាក់ដែលអ្នកគិតថានឹងប្រើប្រាស់ជាក់ស្តែងសម្រាប់ការទូទាត់ដោយផ្អែកលើប្រវត្តិនៃការប្រើប្រាស់។

## 3 ការដាក់ពាក្យស្នើរសុំទៅកាន់ភ្នាក់ងារផ្ទេរប្រាក់ដែលបានកំណត់

● បន្ទាប់ពីមានការយល់ព្រមពីនិយោជក សូមស្នើរការប្រើប្រាស់ការទូទាត់ប្រាក់ឈ្នួលដោយប្រព័ន្ធឌីជីថល ដោយកម្មវិធីរបស់ភ្នាក់ងារផ្ទេរប្រាក់ដែលបានកំណត់។
បន្ទាប់ពីដាក់ពាក្យស្នើរការប្រើប្រាស់ទៅកាន់ភ្នាក់ងារផ្ទេរប្រាក់ដែលបានកំណត់រួច អាចនឹងតម្រូវអោយអ្នកចាំបាច់ផ្តល់ដំណឹងទៅកាន់និយោជក។



ដើម្បីអាចទទួលបាននូវការទូទាត់សងភ្លាមៗនៃសមតុល្យគណនីរបស់អ្នក ក្នុងករណីដែលភ្នាក់ងារផ្ទេរប្រាក់ដែលបានកំណត់បានក្ស័យធនជាដើម នៅក្នុងនីតិវិធីដាក់ពាក្យស្នើរ ការប្រើប្រាស់ត្រូវធ្វើកិច្ចសន្យាធានាដោយអ្នកទាំងអស់គ្នាដែលជាកម្មករនិយោជិតជាមួយនឹងស្ថាប័នធានា។

## នីតិវិធីខាងលើបានបញ្ចប់
## សូមពិនិត្យមើលខ្លឹមសារនៅទំព័របន្ទាប់ផងដែរ

នីតិវិធីដែលចាំបាច់អាចមានភាពខុសគ្នាអាស្រ័យលើភ្នាក់ងារផ្ទេរប្រាក់ដែលបានកំណត់។សម្រាប់ព័ព័ត៌មានលម្អិតសូមពិនិត្យមើលគេហទំព័រនៃភ្នាក់ងារផ្ទេរប្រាក់ដែលបានកំណត់នីមួយៗ។

## 2 ព័ត៌មានគណនីជំនួសដែលបានកំណត់ត្រូវស្ថិតក្នុងស្ថានភាពថ្មីបំផុត!

- សម្រាប់គណនីជំនួសដែលបានកំណត់ ប្រសិនបើសមតុល្យគណនីលើសពីចំនួនអតិបរមាដែលអាចទទួលបានចំនួនទឹកប្រាក់ដែលលើសនោះនឹងត្រូវដកដោយស្វ័យប្រវត្តិ ហើយគណនីប្រាក់សន្សំគឺជាគណនីសំខាន់នៅក្នុងការសងត្រលប់មកវិញនូវសមតុល្យសាច់ប្រាក់ ក្នុងករណីភ្នាក់ងារផ្ទេរប្រាក់ដែលបានកំណត់ក្ស័យធន។ក្នុងករណីដែលមានការផ្លាស់ប្តូរឈ្មោះដោយការប្តូរឈ្មោះប្តូរត្រកូលជាដើម ឬប្រសិនបើគណនីសន្សំដែលបានចុះឈ្មោះលែងមាន

  សុពលភាពដោយសារការលុបចោលជាដើម ការដកប្រាក់និងការទូទាត់សងអាចនឹងចំណាយពេលខ្លះ។ ដូច្នេះ សូមពិនិត្យមើលព័ត៌មានគណនីជំនួសដែលបានកំណត់របស់អ្នកអោយបានទៀតទាត់។

- ប្រសិនបើមានការផ្លាស់ប្តូរណាមួយនៃគណនីជំនួសដែលបានកំណត់ សូមផ្តល់ដំណឹងទៅកាន់ភ្នាក់ងារផ្ទេរប្រាក់ដែលបានកំណត់។

## 3 ករណីឈប់ប្រើការទូទាត់ប្រាក់ឈ្នួលតាមប្រព័ន្ធឌីជីថលឬករណីផ្លាស់ប្តូរឬឈប់ពីការងារ・・・

- ក្រៅពីនិយោជក ក៏មានករណីចាំបាច់ត្រូវជូនដំណឹងដល់ភ្នាក់ងារផ្ទេរប្រាក់ដែលបានកំណត់ផងដែរ។

- ទាក់ទងនឹងកិច្ចសន្យាធានាដែលបានធ្វើជាមួយស្ថាប័នធានាផងដែរអាចនឹងមានការលុបចោល។សម្រាប់នីតិវិធីនៃការលុបចោលកិច្ចសន្យាក៏មានករណីចាំបាច់ក្នុងការទាក់ទងឬជូនដំណឹងទៅកាន់ស្ថាប័នធានាផងដែរ។

  ※សម្រាប់ព័ត៌មានលម្អិតសូមពិនិត្យបញ្ជាក់ជាមួយភ្នាក់ងារផ្ទេរប្រាក់ដែលបានកំណត់។

## 4 ប្រសិនបើមានករណីណាមួយកើតឡើង ・・・

### ■ ករណីមានប្រតិបត្តិការដែលគ្មានការអនុញ្ញាត(ការដកប្រាក់ដោយមិនដឹង។ល។)

ប្រសិនបើម្ចាស់គណនីមិនមានកំហុសទេទឹកប្រាក់ដែលខាតបង់ទាំងអស់នឹងត្រូវផ្តល់ជាសំណង។ ប៉ុន្តែចាំបាច់ត្រូវផ្តល់ដំណឹងទៅកាន់ភ្នាក់ងារផ្ទេរប្រាក់ដែលបានកំណត់ក្នុងពេលកំណត់(ឧទាហរណ៍: 30ថ្ងៃបន្ទាប់ពីថ្ងៃដែលបានបាត់បង់)។
ដូច្នេះ ប្រសិនបើមានប្រតិបត្តិការដែលគ្មានការអនុញ្ញាត

សូមសាកសួរទៅកាន់ភ្នាក់ងារផ្ទេរប្រាក់ដែលបានកំណត់ភ្លាមៗ។

### ■ ករណីភ្នាក់ងារផ្ទេរប្រាក់ដែលបានកំណត់ក្ស័យធន

ដោយផ្អែកទៅលើកិច្ចសន្យាធានាដែលបានធ្វើជាមួយស្ថាប័នធានា សមតុល្យគណនីនឹងត្រូវទូទាត់សងត្រលប់ភ្លាមៗ។ សម្រាប់ការទូទាត់សងត្រលប់វិញ ក្នុងករណីខ្លះចំនួនទឹកប្រាក់ដែលត្រូវសងត្រលប់ត្រូវបានផ្ទេរពីស្ថាប័នធានាទៅគណនីជំនួសដែលបានកំណត់ ហើយក៏មានករណីខ្លះទៀតត្រូវធ្វើការស្នើរទៅកាន់ស្ថាប័នធានាដោយខ្លួនឯងផងដែរ។

※សម្រាប់ព័ត៌មានលម្អិតសូមពិនិត្យបញ្ជាក់ជាមួយភ្នាក់ងារផ្ទេរប្រាក់ដែលបានកំណត់ឬស្ថាប័នធានា

ដើម្បីការរស់នៅនិងអនាគតនៃមនុស្ស
ក្រសួងសុខាភិបាល ការងារ
និងសុខុមាលភាព